ព្រឹទ្ធសភា

អគ្គលេខាធិការដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍

# ស្តីពី

# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែកុម្ភៈ និងទិសដៅការងារខែមីនា ឆ្នាំ២០១៦

## I.សេចក្តីផ្តើម :

នៅក្នុងខែកុម្ភៈនេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានខិតខំបំពេញការងារយ៉ាងសកម្ម និងមមាញឹកលើគ្រប់ការដ្ឋាន ដើម្បីផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក-សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនបានល្អប្រសើរតាមរយៈលទ្ធផលសំខាន់ៗដូចខាងក្រោមនេះ៖

## II.លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា :

### ១.មុខងារនីតិកម្ម:

| របនាសម្ព័ន្ធនយោបាយ | របនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - ប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន ០១លើក និងប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០១លើក ដើម្បីពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ចំនួន០១<br>- ប្រជុំអន្តរគណៈកម្មការព្រឹទ្ធសភាជាមួយតំណាង រាជរដ្ឋាភិបាល ចំនួន០១លើក<br>- ប្រជុំគណៈកម្មការពិសេស ដើម្បីពិនិត្យសិក្សា និងរៀបចំសេចក្តីស្នើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាចំនួន ០២លើក ។ | - រៀបចំទីកន្លែងប្រជុំ បដិសណ្ឋារកិច្ច និងផ្តល់សេវាគាំទ្របម្រើកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន ០១លើក ប្រជុំពេញអង្គចំនួន០១លើក ប្រជុំជាមួយតំណាងរាជរដ្ឋាភិបាលចំនួន០១លើក និងប្រជុំគណៈកម្មការពិសេសចំនួន០២លើក<br>- បានរៀបចំរបាយការណ៍ ស្តីពីការពិនិត្យសិក្សាសេចក្តីព្រាងច្បាប់ចំនួន០១<br>- បញ្ជូនលិខិតទៅក្រៅស្ថាប័នចំនួន៥៨ច្បាប់<br>- បានផ្គត់ផ្គង់សម្ភារៈ ភេសជ្ជៈ និងអាហារសម្រន់ចំនួន០៩សំណើ (៥៣៣នាក់)<br>- ថតចម្លងឯកសារចំនួន០៣សំណើ (អស់ក្រដាសចំនួន៦១៦សន្លឹក) និងផ្តល់សេវាដឹកជញ្ជូនក្នុងរាជធានីបានចំនួន០១លើក (ចំនួន០១នាក់) |



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

| | |
|---|---|
| | - ផ្តល់សេវាសន្តិសុខ ការពារសុវត្ថិភាព និងរៀបចំសណ្តាប់ធ្នាប់ក្នុងបរិវេណព្រឹទ្ធសភា ដោយប្រើកម្លាំងចំនួន៤២នាក់ និងកម្លាំងអន្តរាគមន៍មកពីខាងក្រៅចំនួន១២៦នាក់<br>- បន្តធ្វើបច្ចុប្បន្នភាពបញ្ជីច្បាប់ ដែលព្រឹទ្ធសភាបានពិនិត្យ និងឲ្យយោបល់តាមឆ្នាំ និងនីតិកាល<br>- ធ្វើសេចក្តីជូនដំណឹង និងផ្សព្វផ្សាយលទ្ធផលកិច្ចប្រជុំចំនួន១០លើក ផ្សព្វផ្សាយទៅតាមសារព័ត៌មាន ស្ថានីយទូរទស្សន៍ បង្ហោះលើគេហទំព័រ ថតសម្លេង និងថតកាម៉េរ៉ាវីដេអូចំនួន១០លើក និងផលិតVideo online ចំនួន៣៦លើក និងបំពាក់ម៉េក្រូហ្វូនថ្មីចំនួន០២ឈុត<br>- ប្រជុំក្រុមការងារបច្ចេកទេស ដើម្បីពិនិត្យសិក្សាស្រាវជ្រាវ និងរៀបចំសេចក្តីព្រាងសេចក្តីស្នើបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និងសិក្សាស្រាវជ្រាវរៀបចំសេចក្តីព្រាងក្រមសីលធម៌សមាជិកព្រឹទ្ធសភា<br>- បានផ្តល់សេវាស្រាវជ្រាវ និងរៀបចំឯកសារជំនួយស្មារតីសេចក្តីព្រាងច្បាប់ចំនួន០២ច្បាប់ និងស្រាវជ្រាវលើប្រធានបទសំខាន់ៗពាក់ព័ន្ធនឹងតម្រូវការចាំបាច់របស់ស្ថាប័នចំនួន១៧ប្រធានបទ។ |

**២.មុខងារតំណាង** :

| រចនាសម្ព័ន្ធនយោបាយ | រចនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីបុណ្យមាឃបូជា នៅព្រះមហាសក្យមុនីចេតិយ (ឧត្តុង្គ) ខេត្តកណ្តាល | - ថ្នាក់ដឹកនាំ និងមន្ត្រីរាជការអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន១០០នាក់បានចូលរួមក្នុងពិធីបុណ្យមាឃបូជា នៅឧបដ្ឋានសាលា មុខព្រះមហាសក្យមុនីចេតិយ ភ្នំព្រះរាជទ្រព្យ (ឧត្តុង្គ) ខេត្តកណ្តាល<br>- ធ្វើកំណត់បង្ហាញពាក្យបណ្តឹង ចំនួន១៦ករណី |

| | |
|---|---|
| - ព្រឹទ្ធសភាបានទទួលពាក្យបណ្តឹងចំនួន១៦ករណី លិខិតអន្តរាគមន៍ទៅស្ថាប័នមានសមត្ថកិច្ចដោះស្រាយចំនួន០៦ករណី ទទួលលិខិតឆ្លើយតបទៅម្ចាស់បណ្តឹងចំនួន០៥ករណី និងទទួលឯកសារជូនជ្រាបពីក្រសួង-ស្ថាប័នពាក់ព័ន្ធចំនួន០២ករណី<br>- ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ បានចុះស្រាវជ្រាវ និងប្រមូលព័ត៌មាននៅខណ្ឌទួលគោកចំនួន០១លើក<br>- ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ បានរៀបចំវេទិកាថ្នាក់ខេត្តចំនួន០១លើក ស្តីពីលើកកម្ពស់ និងជំរុញការអភិវឌ្ឍឃុំ-សង្កាត់ នៅខេត្តបាត់ដំបង<br>- ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ បានចុះតាមដានលទ្ធផលក្រោយពីការរៀបចំវេទិកាចំនួន០៣លើក មានអ្នកចូលរួមចំនួន៤៥នាក់ នៅខេត្តរតនគិរី ខេត្តមណ្ឌលគិរី និងខេត្តព្រះវិហារ<br>- សមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ ទី២ ទី៣ ទី៤ ទី៥ និងទី៦ បានប្រជុំផ្ទៃក្នុងចំនួន០៨លើក និងប្រជុំជាមួយគណៈកម្មការទី២ ស្តីពីថវិកាប្រចាំភូមិភាគ សម្រាប់ឆ្នាំ២០១៦<br>- សមាជិក សមាជិកាព្រឹទ្ធសភា បានចុះទៅតាមបណ្តាខេត្ត-រាជធានីទូទាំងប្រទេស ចំនួន១៥៧លើក ដើម្បីចុះ | ឆ្លើយតបម្ចាស់បណ្តឹងជូនជ្រាបចំនួន០២ករណី បញ្ជូនពាក្យបណ្តឹងចេញទៅក្រសួង ខេត្ត និងស្ថាប័នពាក់ព័ន្ធចំនួន១៦ករណី ឆ្លើយតបទៅម្ចាស់បណ្តឹងចំនួន០៥ករណី និងបានទទួលពាក្យបណ្តឹងជូនជ្រាបចំនួន០២ករណី<br>- បានផ្តល់សេវារដ្ឋបាល ពិធីការ និងទំនាក់ទំនងក្នុងដំណើរការចុះស្រាវជ្រាវប្រមូលព័ត៌មាន ពិភាក្សាការងារ និងកម្មវិធីផ្សេងៗចំនួន១៣លើក<br>- សហការរៀបចំទីកន្លែងសម្រាប់វេទិកាចំនួន០១លើក នៅខេត្តបាត់ដំបង មានអ្នកចូលរួមចំនួន៣៤០នាក់<br>- មន្ត្រីនាយកដ្ឋានភូមិភាគចំនួន១៣នាក់ បានចុះបេសកកម្ម ពិភាក្សាការងារជាមួយថ្នាក់រដ្ឋបាលសាលាខេត្ត និងអង្គភាពជំនាញ ដើម្បីត្រៀមរៀបចំវេទិកានៅខេត្តបាត់ដំបង<br>- ធ្វើលិខិតបេសកកម្មចំនួន៤៤ច្បាប់ ជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីអមដំណើរចំនួន១៥៥នាក់<br>- ថតចម្លងឯកសារ ចំនួន០១សំណើ (អស់ក្រដាសចំនួន៥១៩៨សន្លឹក) និងផ្តល់សេវាដឹកជញ្ជូនក្នុងរាជធានីចំនួន១០លើក និងតាមបណ្តាខេត្តទាំង៨ភូមិភាគបានចំនួន០៨លើក សរុបចំនួន១៨លើក (ចំនួន១៩៣នាក់)<br>- បានស្រាវជ្រាវ និងប្រមូលព័ត៌មាន ស្តីពីបាតុភាពផ្សេងៗ នៅផ្សារបានលុង ខេត្តរតនគិរី<br>- បានរៀបចំផែនការសកម្មភាពប្រចាំឆ្នាំ២០១៦ របស់សមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទាំង៨ និងក្រុមសមាជិកាព្រឹទ្ធសភា<br>- ទទួលលិខិតចូលចំនួន៨៨៦ច្បាប់ និងបញ្ជូនលិខិត |

| | |
|---|---|
| ជួបពិភាក្សាការងារ សំណេះសំណាល សាកសួរសុខទុក្ខ ប្រជាពលរដ្ឋ កងទ័ព សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្ត ចុះពិនិត្យព្យាបាលជំងឺជូនប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ-ឃុំ មានសុវត្ថិភាព ស្វែងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗសរុប ចំនួន៤៦លើក ។ | ចេញចំនួន១៤២២ច្បាប់<br>- ផ្តល់សេវាប្រព័ន្ធ Internet ថត និងយកព័ត៌មាន សកម្មភាពថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងផ្សព្វផ្សាយទៅតាមសារព័ត៌មាន ស្ថានីយទូរទស្សន៍ និងគេហទំព័រព្រឹទ្ធសភា ចំនួន២១លើក<br>- រៀបចំផលិតសារជូនពរ ប័ណ្ណជូនពរ ចូលឆ្នាំខ្មែរ ប្រពៃណីជាតិខ្មែរ និងរៀបចំពិព័រណ៍ ស្តីពីសកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាប្រចាំខែកុម្ភៈ ឆ្នាំ២០១៦ និងរៀបចំផលិតវីដេអូ ស្តីពីសមិទ្ធផលរយៈពេល១ឆ្នាំរបស់ព្រឹទ្ធសភា ដើម្បីផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍<br>- ប្រគល់សៀវភៅទិនានុលេខន៍ចំនួន៤១០ក្បាល ប្រតិទិនផែនការខែខ្នាតA3 ចំនួន១០០ក្បាល ផ្តល់រូបថត រូបភាព ១៧៧សន្លឹក និងឯកសារព្រឹត្តិបត្រ-អត្ថបទសារព័ត៌មានចំនួន៤៧អត្ថបទ<br>- ទទួលមន្ត្រីរាជការ សិស្សនិស្សិត និងសាធារណជនចូលអានសៀវភៅចំនួន១៨៩នាក់ ប្រើប្រាស់ Internet ចំនួន៦៥នាក់ ខ្ចីសៀវភៅចំនួន៣៧ក្បាល និងសងវិញចំនួន៤២ក្បាល ធ្វើប័ណ្ណសមាជិកបណ្ណាល័យប្រគេនព្រះសង្ឃ និងសិស្ស និស្សិត ចំនួន០៤នាក់<br>- ទទួលឯកសារ សៀវភៅពីអង្គការ ស្ថានទូត ស្ថាប័ន ក្រសួង គ្រឹះស្ថានអប់រំ សប្បុរសជន និងអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន ៣០១ក្បាល ព្រឹត្តិបត្រចំនួន៨៥ ទស្សនាវដ្តីចំនួន០៣ក្បាល ព្រះរាជក្រមចំនួន០៨ច្បាប់ |

| | |
|---|---|
| | ព្រះរាជកិច្ចចំនួន៣០ក្បាល ផ្តល់ និងផ្សព្វផ្សាយសៀវភៅ និងឯកសារផ្សេងៗ របស់ព្រឹទ្ធសភា ជូនវិទ្យាល័យ សាកលវិទ្យាល័យ អង្គការ ក្រសួងស្ថាប័ន និងបណ្ណាល័យនានាចំនួន១២៩៣ក្បាល<br>- ដកស្រង់ និងចងក្រងអត្ថបទ-ព្រឹត្តិបត្រទស្សនព័ត៌មាន និងបានផ្សព្វផ្សាយប្រចាំថ្ងៃចំនួន១៦៨ ច្បាប់ ។ |

**៣.មុខងារតាមដានការអនុវត្តច្បាប់** :

| វចនាសម្ព័ន្ធនយោបាយ | វចនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - គណៈកម្មការទី១ បានជួបសវនាការជាមួយតំណាងការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា និងក្រសួងយុត្តិធម៌<br>- សមាជិកាព្រឹទ្ធសភា ចុះទៅតាមដានការអនុវត្តច្បាប់នៅខេត្តព្រះវិហារ និងខេត្តមណ្ឌលគិរីចំនួន០១លើក ។ | - បានចាត់ចែងនីតិវិធី ឯកសារពាក់ព័ន្ធ និងធ្វើកំណត់ហេតុ របាយការណ៍កិច្ចប្រជុំគណៈកម្មការនានា ចំនួន០៥លើក<br>- បានតាមដានព័ត៌មាន សិក្សាស្រាវជ្រាវ និងធ្វើតារាងសង្ខេបស្តីពីវឌ្ឍភាពការងារ របស់ក្រសួង-ស្ថាប័ននានាចំនួន០១លើក<br>- ធ្វើលិខិតបេសកកម្មចំនួន០២ច្បាប់ និងបញ្ជូនលិខិតទៅក្រៅស្ថាប័នព្រឹទ្ធសភាចំនួន២៤ច្បាប់ ផ្តល់សេវាដឹកជញ្ជូនក្នុងរាជធានី និងតាមបណ្តាខេត្តទាំង៨ភូមិភាគ ចំនួន០៤លើក (ចំនួន០៨នាក់)<br>ចុះយកព័ត៌មាន និងថតសកម្មភាពការងាររបស់សមាជិកព្រឹទ្ធសភា ។ |

**៤.មុខងារសហប្រតិបត្តិការអន្តរជាតិ និងទំនាក់ទំនងសាធារណៈ** :

| វចនាសម្ព័ន្ធនយោបាយ | វចនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - ជំនួបរវាងសម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា ជាមួយឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសហរដ្ឋអាមេរិកប្រចាំកម្ពុជា | - បានរៀបចំពិធីបដិសណ្ឋារកិច្ច ដំណើរទស្សនកិច្ចផ្លូវការ និងចូលរួមកិច្ចប្រជុំផ្សេងៗរបស់គណៈប្រតិភូព្រឹទ្ធសភា<br>- រៀបចំតុបតែងលម្អទីកន្លែង ទង់ជាតិ វត្ថុអនុស្សាវរីយ៍ |

| | |
|---|---|
| ប្រធានមូលនិធិខុនរ៉ាដអាឌិនណៅអ៊ែរ គណៈប្រតិភូគណៈកម្មាធិការសិទ្ធិ មនុស្ស នៃសហភាពអន្តរសភា(IPU)<br>- គណៈកម្មការទី១ព្រឹទ្ធសភា បានជួបពិភាក្សាការងារជាមួយរដ្ឋសភា និងគណៈប្រតិភូគណៈកម្មាធិការសិទ្ធិមនុស្សនៃសហភាពអន្តរសភា (IPU)<br>- ប្រធានគណៈកម្មការទី៥ បានជួបពិភាក្សាការងារជាមួយនាយិកាគម្រោងកម្មវិធី NORIA នៃសភាប្រើប្រាស់ភាសាបារាំង<br>- ថ្នាក់ដឹកនាំ សមាជិក-សមាជិកាព្រឹទ្ធសភា បានទៅបំពេញទស្សនកិច្ចផ្លូវការនៅព្រះរាជាណាចក្រជប៉ុន ទស្សនកិច្ចសិក្សានៅគណៈបញ្ជាការដ្ឋានសន្តិសុខជាតិប្រចាំទិសនិរតី នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ចូលរួមកិច្ចប្រជុំស្តីពីការដោះស្រាយបញ្ហាប្រឈមដ៏សំខាន់ក្នុងពេលបច្ចុប្បន្ន តួនាទីរបស់រដ្ឋាភិបាល សង្គមស៊ីវិល និងអង្គភាពផ្អែកទៅលើជំនឿ ដោយអង្គការ(UPF) នៅសាធារណរដ្ឋកូរ៉េ និងចូលរួមកិច្ចប្រជុំនៅប្រទេសម៉ាឡេស៊ី ។ | ចាត់ចែងអ្នកបកប្រែប្រព័ន្ធផ្សព្វផ្សាយ<br>- បម្រើភេសជ្ជៈ និងអាហារសម្រាប់ក្នុងពិធីផ្សេងៗ សរុបចំនួន០៦លើក (ចំនួន៨២នាក់)<br>- ទំនាក់ទំនងជាមួយស្ថានទូតបណ្តាប្រទេសជាមិត្ត ដើម្បីសម្រួលបែបបទ និងកម្មវិធីទស្សនកិច្ច ធ្វើកំណត់បង្ហាញ កំណត់ហេតុ កំណត់ទូត និងជំនួយស្មារតី រៀបចំបែបបទបើកបន្ទប់(VIP) នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ជូន-ទទួលដំណើរបេសកកម្មសរុបចំនួន២៦លើក<br>- ចេញលិខិតបេសកកម្មជូនសមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការចំនួន០៧ច្បាប់ និងបញ្ជូនទៅក្រៅស្ថាប័នព្រឹទ្ធសភាចំនួន៤០ច្បាប់<br>- ថតចម្លងឯកសារបានចំនួន០៣សំណើ (ក្រដាសចំនួន១១២០សន្លឹក) ផ្តល់សេវាដឹកជញ្ជូនក្នុងរាជធានី និងតាមបណ្តាខេត្តទាំង៨ ចំនួន២៩លើក (ចំនួន១១៥នាក់)<br>- ការពារ និងរៀបចំសណ្តាប់ធ្នាប់ ដោយប្រើប្រាស់កម្លាំងសរុបចំនួន៧១នាក់<br>- ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា ជួបពិភាក្សាការងារជាមួយមូលនិធិខុនរ៉ាដអាឌិនណៅអ៊ែថ្មី (KAS) និងលេខាទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា<br>- ទំនាក់ទំនងជាមួយសភារ៉ូឡូនី ព្រុចសែល-បែលហ្ស៊ិក ស្ថានទូតចិន អង្គការមូលនិធិ Marc Plan អន្តរជាតិ, អង្គការ KAS, SES, GIZ, JDS, UNESCO, CIM, លោកស្រីMireille EZA ប្រធានគម្រោងកម្មវិធី Noria ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង សមាគមមនុស្សធម៌ |

| | |
|---|---|
| | សមាគមអគ្គលេខាធិការនិយាយភាសាបារាំង វិទ្យាស្ថានសភាកម្ពុជា អគ្គលេខាធិការដ្ឋានរដ្ឋសភា សាលាភូមិន្ទរដ្ឋបាល ការិយាល័យអាហារូបករណ៍អូស្ត្រាលី សង្គមស៊ីវិល អាកាសចរណ៍ស៊ីវិល អគ្គស្នងការនគរបាលជាតិ សាលាខេត្តព្រះសីហនុ កំពង់ផែស្វយ័ត និងក្រសួង-ស្ថាប័ននានាសម្រាប់ដំណើរទស្សនកិច្ច សិក្ខាសាលា និងបំពេញបេសកកម្មផ្សេងៗ ស្នើសុំអាហារូបករណ៍ និងវគ្គបណ្តុះបណ្តាលផ្សេងៗ ជាពិសេសបានទំនាក់ទំនងជាមួយបណ្ណាល័យសភាកូរ៉េ និងក្រុមហ៊ុន KH4IT សិក្សាពីបណ្ណាល័យអេឡិចត្រូនិច និងលើកគម្រោង Lab និងបន្ទប់ Video Room ។ |

**៥.មុខងារអភិវឌ្ឍន៍ស្ថាប័ន** :

| របនាសម្ព័ន្ធនយោបាយ | របនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - ព្រឹទ្ធសភាទទួលបានជំនួយអគារខុទ្ទកាល័យថ្នាក់ដឹកនាំព្រឹទ្ធសភាពីរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតចិន។ | - ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា បានពិនិត្យផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៦៨៥ច្បាប់<br>+ការងារគ្រប់គ្រងបុគ្គលិក :<br>- ប្រជុំគណៈកម្មការពិនិត្យការវាយតម្លៃតម្លើងថ្នាក់បៀវត្សជូនមន្ត្រីរាជការអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- ធ្វើប័ណ្ណសម្គាល់កម្មករ និងអ្នកបច្ចេកទេសសាងសង់អគារជំនួយចិន អគាររដ្ឋធម្មនុញ្ញ អគារវិទ្យាស្ថានសភាកម្ពុជា(PIC) ចំនួន៤៧នាក់<br>- បានធ្វើលិខិតបទដ្ឋានផ្សេងៗពាក់ព័ន្ធនឹងការគ្រប់គ្រងមន្ត្រីរាជការ សរុបចំនួន១១៣ច្បាប់ |

| | |
|---|---|
| | +ការងារបណ្តុះបណ្តាលធនធានមនុស្ស : <br>- ការបណ្តុះបណ្តាលធនធានមនុស្សនៅក្នុង-ក្រៅប្រទេសសរុបចំនួន០៨វគ្គ សិក្ខាកាមចំនួន៧៧នាក់ <br>- កសាងផែនការបណ្តុះបណ្តាល និងអភិវឌ្ឍន៍ធនធានមនុស្សនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភារយៈពេល០៥ឆ្នាំ (២០១៧-២០២១) <br>+ចាត់ចែងការងារកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ : <br>- ការរៀបចំថវិកាតាមកម្មវិធីឆ្នាំ២០១៦ <br>- ប្រជុំសម្រេចអំពីការងារលទ្ធកម្មសាធារណៈ (សំលៀកបំពាក់ សម្ភារការិយាល័យ បោះពុម្ព និងប្រេងឥន្ធនៈ) <br>- បានរៀបចំរបាយការណ៍ចំនួនមន្ត្រីក្របខ័ណ្ឌ និងមន្ត្រីមិនមែនក្របខ័ណ្ឌ របាយការណ៍ប្រាក់បៀវត្ស ប្រាក់បំណាច់ និងប្រាក់វិភាគផ្សេងៗ និងរបាយការណ៍ចំណាយថវិកាធៀបអាណត្តិប្រចាំខែកុម្ភៈ ឆ្នាំ២០១៦ ផ្ញើជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ <br>- បានធ្វើកម្មវិធីចំណាយសម្រាប់ត្រីមាសទី២ ឆ្នាំ២០១៦ ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ <br>- បានផ្តល់សេវាភេសជ្ជៈ សរុបចំនួន១៥លើក (ចំនួន៤៩២នាក់) និងតាំងផ្កាក្នុងពិធីផ្សេងៗ ចំនួន១២លើក <br>+ការកសាង និងជួសជុលហេដ្ឋារចនាសម្ព័ន្ធរូបវន្តរឹង និងទន់ : <br>- រៀបចំដំណើរការការដ្ឋានសាងសង់អគារខុទ្ទកាល័យថ្នាក់ដឹកនាំព្រឹទ្ធសភា |

| | |
|---|---|
| | - រៀបចំទិន្នន័យ និងប្លង់: អគ្គិសនី លូទឹក ប្រព័ន្ធទឹកស្អាត ផ្លូវថ្នល់ ការជួសជុលកែលម្អអគារបណ្ណាល័យ និងការរៀបចំកែលម្អសួនច្បារថ្មី<br>- រុះរើឃ្លាំងដែក ជួសជុលទ្វារឈើ ទ្វារដែក សោទ្វារចំនួន៣៧វង់/គ្រឿង<br>- ជួសជុល ផ្លាស់ប្តូរគ្រឿងអគ្គិសនី និងគ្រឿងអេឡិចត្រូនិច សរុបចំនួន៤៣គ្រឿង បន្ទប់ទឹក និងបណ្តាញទឹកចំនួន១៤លើក<br>- សហការរៀបចំ និងប្រចាំការម៉ាស៊ីនភ្លើងនៅតាមសាលប្រជុំចំនួន១១លើក និងរៀបចំសណ្តាប់ធ្នាប់រថយន្តគ្រប់ប្រភេទនៅក្នុងព្រឹទ្ធសភាចំនួន២១លើក<br>- រៀបចំដំណើរការប្រព័ន្ធព័ត៌មានវិទ្យា (ICT) ជាមួយក្រុមបច្ចេកទេសវៀតណាម<br>- រៀបចំប្រព័ន្ធម៉េក្រូហ្វូន និងប្រព័ន្ធសម្លេងសម្រាប់ជំនួបពិភាក្សាការងារ កិច្ចប្រជុំ សិក្ខាសាលា ក្នុងកម្មវិធីផ្សេងៗចំនួន០៨លើក<br>- ចុះត្រួតពិនិត្យ តាមដានប្រព័ន្ធNetwork, Internet, Connect Wifi ចំនួន៣៦លើក និងជួសជុលម៉ាស៊ីនកុំព្យូទ័រ ដាក់កម្មវិធីកំចាត់មេរោគ Update Files Antivirus បញ្ចូលកម្មវិធីUnicode និងSet up កម្មវិធីសរុបចំនួន៧០គ្រឿង ។ រៀបចំមាតិកា និង Upload រូបភាពសកម្មភាពការងារសមាជិកព្រឹទ្ធសភា សរុបចំនួន៥៨ប្រធានបទ<br>+ការងារផ្សេងៗ :<br>- បញ្ចូលសៀវភៅជាភាសាអង់គ្លេសក្នុងកម្មវិធីបណ្ណាល័យខ្ញុំចំនួន៩០ក្បាល និងធ្វើសេចក្តីជូនដំណឹងណែនាំផ្សេងៗ ស្តីពីការរៀបចំតម្កល់ឯកសារ |

| | |
|---|---|
| | ឲ្យមានសន្តិសុខ សុវត្ថិភាព គង់វង្សបានយូរអង្វែង<br>- ស្រាវជ្រាវឯកសារព័ត៌មាន និងសេចក្តីព្រាងច្បាប់ NGOs និងចងក្រងបញ្ជីឈ្មោះអង្គការជាតិ-អន្តរជាតិ ។ |

## III.ទិសដៅការងារខែមីនា ឆ្នាំ២០១៦

### ១.មុខងារនីតិកម្ម:

-ត្រៀមរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងសម័យប្រជុំពេញអង្គព្រឹទ្ធសភា

-សិក្សាច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិកព្រឹទ្ធសភា តាក់តែងក្រមសីលធម៌ និងបទបញ្ជាផ្ទៃក្នុងថ្មី។

### ២.មុខងារតំណាង :

-ត្រៀមរៀបចំវេទិកាតាមភូមិភាគ សិក្ខាសាលា និងពិធីសំណេះសំណាលផ្លូវការផ្សេងៗ ។

### ៣.មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយ :

-ត្រៀមសម្រួលការជួបសវនាការរវាងគណៈកម្មការជំនាញ និងក្រសួងស្ថាប័ននានា និងការចុះបេសកកម្មតាមបណ្តាខេត្ត-ក្រុង ។

### ៤.មុខងារសហប្រតិបត្តិការអន្តរជាតិ និងទំនាក់ទំនងសាធារណៈ

-ត្រៀមរៀបចំពិធីជំនួបរវាងថ្នាក់ដឹកនាំជាមួយគណៈប្រតិភូបរទេស និងអង្គទូតនានា ( ទូតគុយបា ស្វីស និងទូតប៉ូឡូញ)

-ត្រៀមទទួលបដិសណ្ឋារកិច្ចគណៈប្រតិភូជាន់ខ្ពស់ព្រឹទ្ធសភារុស្ស៊ី

-ត្រៀមរៀបចំបែបបទជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា បំពេញបេសកកម្មក្រៅប្រទេស រួមទាំងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ៖

+ប្រជុំសន្និបាត (IPU) នៅប្រទេស Zambia

+មន្ត្រី០១នាក់ ចូលរួមកម្មសិក្សានៅប្រទេសបារាំង

-សិក្ខាសាលាសហការជាមួយអង្គការ UNESCO ការសម្តែងសិល្បៈ ដើម្បីអបអរទិវាហ្វ្រង់កូហ្វូនី និងសិក្ខាសាលា ដើម្បីផ្សព្វផ្សាយអំពីបែបបទហិរញ្ញវត្ថុជាមួយវិទ្យាស្ថានសភាកម្ពុជា(PIC)

-បន្តសកម្មភាពសហប្រតិបត្តិការការងារជាមួយដៃគូនានា៖ SES, CIM, KAS, GIZ, MARC PLAN FOUNDATION, UNESCO និងKOICA

-បន្តសហការជាមួយវិទ្យាស្ថានសភាកម្ពុជា អំពីជំហានរៀបចំការិយាល័យ PBO និងការពង្រីកឥទ្ធិពលតំបន់របស់វិទ្យាស្ថានសភាកម្ពុជាជាមួយសភាឡាវ ថៃ និងភូមាក្នុងក្របខ័ណ្ឌត្បូង-ត្បូង

ការចុះហត្ថលេខាលើកិច្ចសហប្រតិបត្តិការរវាងវិទ្យាស្ថានសភាកម្ពុជា(PIC) និងអគ្គលេខាធិការ AIPA (នាខែមីនា ឆ្នាំ២០១៦)។

**៥.មុខងារអភិវឌ្ឍន៍ស្ថាប័ន :**

- ពិធីបំពាក់គ្រឿងឥស្សរិយយសជូនសមាជិកព្រឹទ្ធសភា

-ការចាប់ផ្តើមរៀបចំប្រព័ន្ធ Website/Webpage ក្នុងកម្រិតអគ្គនាយកដ្ឋាន និងគណៈកម្មការ

-បង្កើនសមត្ថភាពស្រាវជ្រាវអំពីឯកសារបច្ចុប្បន្នភាពរបស់ជាតិ ដើម្បីបង្កើនសមត្ថភាពផ្តល់សេវាព័ត៌មានចាំបាច់

-បន្តកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យតាមប្រព័ន្ធព័ត៌មានវិទ្យា កសាង Program និង Software ដើម្បីអនុវត្តតាមអង្គភាព និងការបណ្តុះបណ្តាល

-បន្តអភិវឌ្ឍន៍ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានតាមកិច្ចសហប្រតិបត្តិការជាមួយវៀតណាម ចិន កូរ៉េ ជប៉ុន ឥណ្ឌា និងការបំពាក់សម្ភារបរិក្ខារជំនួយរបស់សាធារណរដ្ឋសង្គមនិយមវៀតណាម

-បន្តកសាងគោលការណ៍ គោលនយោបាយថ្មី ដើម្បីជាផលប្រយោជន៍ដល់ស្ថាប័ន និងមន្ត្រីរាជការ

-បន្តកសាងគោលការណ៍ណែនាំអំពីការរៀបចំដំណើរទស្សនកិច្ចសិក្សា និងកសាងខ្សែវីដេអូឯកសារ និងបោះពុម្ពឯកសារផ្សេងៗ

-ការរៀបចំពិធីបុណ្យទិវាអន្តរជាតិនារី ៨មីនា

-ចាត់ចែងដំណើរការអង្គភាពនៃសវនកម្មបឋម អង្គភាពផលិតវីដេអូ អង្គភាពផលិតឯកសារផ្សព្វផ្សាយ

-ជំរុញការស្នើសុំអាហារូបករណ៍ និងដាក់ពាក្យប្រលងអាហារូបករណ៍តាមប្រកពពីកូរ៉េ ជប៉ុន សឹង្ហបុរី ថៃ ម៉ាឡេស៊ី និងឥណ្ឌា

-ការងារកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ

-ការរៀបចំថវិកាកម្មវិធីឆ្នាំ២០១៦ តាមអង្គភាពថវិកា និងចាប់ផ្តើមអនុវត្តការកត់ត្រាការចំណាយតាមអង្គភាពថវិកានីមួយៗ

-ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា៣ឆ្នាំរំកិល និងការរៀបចំគម្រោងថវិកាឆ្នាំ២០១៧ ។

## IV.សេចក្តីសន្និដ្ឋាន

ក្នុងខែកុម្ភៈនេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្មលើសេវាទ្រទ្រង់មុខងារនីតិកម្ម បានរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០១លើក និងប្រជុំពេញអង្គចំនួន ០១លើក ដោយបានពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ចំនួន០១ និងផ្តល់សេវាលើមុខងារផ្សេងៗទៀត

ជូនថ្នាក់ដឹកនាំ សមាជិក-សមាជិកាព្រឹទ្ធសភាបានដោយរលូន ។ ដោយឡែកលើមុខងារតំណាង ចុះជួបប្រជាពលរដ្ឋ នៅរាជធានីភ្នំពេញ ខេត្តព្រៃវែង ស្វាយរៀង រតនគិរី កំពង់ស្ពឺ និងបន្ទាយមានជ័យ ព្រមទាំងបានចូលរួមចុះសួរសុខទុក្ខម្ចាស់ឆ្នោតនៅខេត្តនានា ។ ទន្ទឹមនេះលើមុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយ បានចុះបេសកកម្មនៅខេត្តកែប និងកំពត ។ ការអភិវឌ្ឍស្ថាប័ន បានបើកទំព័រថ្មីតាមការបញ្ចូលប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ។ លើការងារកិច្ចសហប្រតិបត្តិការអន្តរជាតិកាន់តែបើកទូលាយ និងមានលទ្ធផលកាន់តែផ្លែផ្កា ជាពិសេសអគ្គលេខាធិការដ្ឋាន បានដើរតួនាទីស្នូលខាងការស្រាវជ្រាវ និងកសាងឯកសារបំរើដំណើរទស្សនកិច្ចរបស់គណៈប្រតិភូជាន់ខ្ពស់ទៅប្រទេសជប៉ុន ដែលបានប្រព្រឹត្តទៅដោយរលូន និងមានលទ្ធផលជាផ្លែផ្កា ។៚

ភ្នំពេញ,ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៦

**អគ្គលេខាធិការ**

**អ៊ុំ.សារិទ្ធ**